ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ព្រហស្បតិ៍ ៦ រោច ខែ ភទ្របទ ឆ្នាំ ច ឯកស័ក ព.ស. ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៩*

**សេចក្តីប្រកាសព័ត៌មានស្តីពី**
**លទ្ធផលនៃវេទិការងាររាជរដ្ឋាភិបាលក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និង អភិបាលកិច្ច “ក្រុម ឃ”**
**ជាមួយវិស័យឯកជន ដើម្បីពិនិត្យដោះស្រាយកង្វល់ និងបញ្ហារបស់វិស័យឯកជន**

នៅព្រឹកថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនិងលោក Bretton G. Scaironi សហប្រធាន “**ក្រុម ឃ**” (ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច) នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន បានដឹកនាំកិច្ចប្រជុំ “**ក្រុម ឃ**” ដោយមានការចូលរួមពីសហសេវិកទាំងខាង ទាំងផ្នែករាជរដ្ឋាភិបាល និងផ្នែកឯកជន និងតំណាងសភាពាណិជ្ជកម្មកម្ពុជាផងដែរ ។ គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីឱ្យរាជរដ្ឋាភិបាលបានពិនិត្យដោះស្រាយលើសំណើ ក៏ដូចជាសំណូមពរដែលជាកង្វល់របស់ផ្នែកឯកជន ។

មុននឹងកិច្ចពិភាក្សា, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងនូវការកោតសរសើរចំពោះសមាជិក សមាជិការទាំងអស់នៃ “**ក្រុម ឃ**” ទាំងផ្នែករាជរដ្ឋាភិបាល និងទាំងផ្នែកឯកជន ដែលបានខិតខំរួមគ្នាពុះពារដោះស្រាយបាននូវបញ្ហាប្រឈម និងកង្វល់ធំៗរបស់វិស័យឯកជន ក៏ដូចជាសម្រេចបាននូវសមិទ្ធផលជាច្រើនពិសេស ជួយកាត់បន្ថយបន្ទុកចំណាយរបស់វិស័យឯកជន រួមចំណែកពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា បង្កើតបរិយាកាសធុរកិច្ច និងវិនិយោគនៅកម្ពុជាឱ្យកាន់តែល្អប្រសើរ ក្នុងគោលដៅធានាចីរភាពនៃកំណើនសេដ្ឋកិច្ច និងភាពធន់មាំសម្រាប់ដំណើររយៈពេលវែងខាងមុខរបស់កម្ពុជា ។ តាមរយៈកិច្ចប្រឹងប្រែងរបស់ក្រុមការងារនីមួយៗ បានធ្វើឱ្យផ្នែកឯកជនបានទទួលផលប្រយោជន៍ច្រើន ដូចបានលើកឡើងនៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៨ កាលពីថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៩ កន្លងមកនេះ ដូចជា៖ កាត់បន្ថយថ្លៃឡូជីស្ទីក, កាត់បន្ថយថ្លៃសេវាលើក-ដាក់នៅកំពង់ផែ, កាត់បន្ថយថ្លៃអគ្គិសនី, ការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ជាដើម ។

កិច្ចការទាំងនេះ បានធ្វើឱ្យវិស័យឯកជនទទួលបានភាពអនុគ្រោះកាន់តែខ្ពស់ដែលបង្ហាញយ៉ាងច្បាស់ពីការយកចិត្តទុកដាក់ខ្ពស់ថែមទៀត និងគាំទ្រយ៉ាងខ្លាំងក្លារបស់រាជរដ្ឋាភិបាលកម្ពុជា ដល់វិស័យឯកជនដែលកំពុងប្រតិបត្តិ-ការធុរកិច្ចនៅកម្ពុជា ។

សំណើធំៗចំនួន ៥ ត្រូវបានលើកមកពិភាក្សា និងដោះស្រាយ រួមមាន៖

***១. ច្បាប់ស្តីពីបរធនបាលកិច្ច៖***

ដោយច្បាប់នេះ ត្រូវបានអនុម័តរួចហើយ, រាជរដ្ឋាភិបាល ក៏បានចេញអនុក្រឹត្យសម្រាប់អនុវត្តច្បាប់នេះរួចហើយដែរ ។ បច្ចុប្បន្ន, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំពុងបន្តរៀបចំប្រកាសសម្រាប់អនុវត្តអនុក្រឹត្យនេះ ដោយត្រូវបន្តពិភាក្សាជាមួយវិស័យឯកជន ។

### *២. សារព្រមានសុខភាពសម្រាប់បិទលើកញ្ចប់បារី÷*

បញ្ហានេះត្រូវបានពិនិត្យ និងឆ្លើយតបយ៉ាងយកចិត្តទុកដាក់ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានរៀបចំបង្កើតក្រុមការងារចម្រុះដែលមានសមាសភាពពីអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាដើម្បីកែលម្អលក្ខណៈពិសេសរបស់តែមប្រ៊ី ចៀសវាងការក្លែងបន្លំ ក៏ដូចជាដើម្បីពិនិត្យអនុលោមភាពលើការលក់បារី ជាមួយនឹងការអនុវត្តទោសទណ្ឌចំពោះអ្នកមិនគោរពតាមគោលការណ៍អនុលោមភាពនេះ ។

### *៣. ការស្នើសុំបញ្ចុះថ្លៃអគ្គិសនីសម្រាប់ក្រុមហ៊ុនប្រតិបត្តិករទូរគមនាគមន៍÷*

គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល គឺការជំរុញការនាំចេញ ។ ដូច្នេះ, ផ្នែកផលិតកម្ម ឧស្សាហកម្មត្រូវបានយកចិត្តទុកដាក់ជាអាទិភាព ខណៈដែលក្រុមហ៊ុនប្រតិបត្តិករទូរគមនាគមន៍ ត្រូវបានចាត់ជាវិស័យពាណិជ្ជកម្ម ។ បច្ចុប្បន្ននេះ, រដ្ឋាភិបាល មិនទាន់មានលទ្ធភាពខ្ពស់ក្នុងការគិតគូរ និងអនុវត្តបញ្ចុះថ្លៃអគ្គិសនីសម្រាប់គ្រប់វិស័យទាំងអស់ព្រមៗគ្នានៅឡើយ ដោយសារថ្លៃដើមផលិតអគ្គិសនីនៅខ្ពស់ អាចបង្កើនបន្ទុកថវិកាជាតិ ដែលអគ្គិសនីកម្ពុជាអាចរងសម្ពាធចំណូល និងប៉ះពាល់ដល់ប្រសិទ្ធភាពក្នុងការពង្រីកបណ្ដាញចែកចាយ ដែលជាគោដៅឆ្នាំ ២០២០ ក្នុងការសម្រេចឱ្យបានការផ្គត់ផ្គង់អគ្គិសនីនៅទូទាំងប្រទេស ។ ទោះយ៉ាងណា វិស័យពាណិជ្ជកម្ម នឹងត្រូវបន្តគិតគូរក្នុងជំហានបន្តបន្ទាប់ ដូចបានអនុវត្តកន្លងមក ។

### *៤. ការចុះបញ្ជីមន្ទីរពេទ្យឯកជននៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម÷*

ដែលករណីនេះត្រូវបានអនុវត្តខ្លះហើយ ក្នុងនោះ មន្ទីរពេទ្យឯកជន ត្រូវបានអនុញ្ញាតឱ្យទូទាត់តាម ប.ស.ស ក្នុងករណីសង្គ្រោះបន្ទាន់ ។ មន្ទីរពេទ្យឯកជនមួយចំនួនដែលមានអ្នកជំងឺច្រើន បានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស និងមានដាក់ស្លាក ប.ស.ស ។ ការចាត់វិធានការបន្ថែមការផ្សព្វផ្សាយគោលនយោបាយជាតិគាំពារសង្គម និងការពិនិត្យលក្ខខណ្ឌគុណភាព និង ការទូទាត់សងសមស្រប ត្រូវបន្តឲ្យកាន់តែទូលំទូលាយថែមទៀត នៅតាមកន្លែងណាត្រូវការជំនួយបន្ថែមពីមន្ទីរពេទ្យ ។

### *៥. ការជំរុញទូទាត់ និងប្រើប្រាស់ប្រាក់រៀល÷*

ស្មារតីនៃការចូលរួម និងជំរុញការទូទាត់ និងការប្រើប្រាស់ប្រាក់រៀល ត្រូវបានទទួលការអបអរសាទរ ។ ជាមួយគ្នានេះ, អង្គភាពពាក់ព័ន្ធ នឹងបន្តសិក្សាពីយុទ្ធសាស្ត្រ ដោយផ្អែកលើគ្រប់ទិដ្ឋភាពទាំងអស់ ដើម្បីជំរុញការប្រើប្រាស់ និងទូទាត់ជាប្រាក់រៀលឲ្យកាន់តែទូលំទូលាយ ក៏ដូចជាផ្ដល់ផលប្រយោជន៍ដល់សង្គម-សេដ្ឋកិច្ចកម្ពុជា ។

បន្ថែមលើរបៀបវារៈធំៗ ចំនួន ៥ ខាងលើ, វេទិកាក៏បានពិភាក្សាលើបញ្ហាធំៗ ចំនួន ៣ ទៀត ដែលវិស័យឯកជនបានលើកឡើងគឺ÷ ការធ្វើសវនកម្មពន្ធដារ និងការស្នើលុបចោលនូវប្រាក់ពិន័យពន្ធ, ការអនុវត្តលើកលែងពន្ធអប្បបរមា ១% និងការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ១% និងការបង់សេវាលើស្លាកយីហោ ។

### *១. ការធ្វើសវនកម្មពន្ធដារ និងការស្នើលុបចោលនូវប្រាក់ពិន័យពន្ធ÷*

ប្រកាសលេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីសវកម្មពន្ធដារ បានលុបបំបាត់ការចុះធ្វើសវនកម្មជាន់គ្នារវាងអង្គភាពជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ ដោយក្នុងនោះមានការបែងចែកការងារសវនកម្មស្របតាមកម្មវិធីសវនកម្ម និងបែកចែកសហគ្រាសដល់នាយកដ្ឋានសវនកម្មសហគ្រាស នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម និងអង្គភាពពាក់ព័ន្ធ សម្រាប់

ចុះធ្វើសវនកម្មដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យច្បាស់លាស់ ។ ជាមួយគ្នានេះ, ប្រកាសក៏បានកំណត់រយៈពេល កំណត់ពន្ធឡើងវិញ សម្រាប់សវនកម្មមានកម្រិត តែក្នុងឆ្នាំជាប់ពន្ធចរន្ត និងឆ្នាំជាប់ពន្ធមុនឆ្នាំចរន្ត ។ សម្រាប់សវនកម្មពេញលេញ ដែលពីមុនអនុញ្ញាតបកក្រោយរហូតដល់ ១០ ឆ្នាំ ត្រូវបានកំណត់បកក្រោយមកត្រឹមតែ ៣ ឆ្នាំ ប៉ុណ្ណោះ ។ រីឯអាត្រាការប្រាក់ប្រចាំខែក៏បានកាត់បន្ថយពី ២% មកត្រឹម ១,៥% ផងដែរ ។

ចំពោះការស្នើឱ្យលុបបំបាត់នូវប្រាក់ពិន័យពន្ធដារ គឺមិនអាចអនុវត្តបាន ដោយការដាក់ពិន័យនេះ គឺដើម្បីលើកកម្ពស់វប្បធម៌នៃការបង់ពន្ធ ក៏ដូចជាលុបបំបាត់ការគេចវេសកាតព្វកិច្ចពន្ធដារ ។

### *២. ការអនុវត្តលើកលែងពន្ធអប្បបរមា ១% និងការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ១%៖*

រាជរដ្ឋាភិបាលបានសម្រេចលើកលែងពន្ធអប្បបរមា ១% ចំពោះគ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលបានបានបំពេញកាតព្វកិច្ចសារពើពន្ធត្រឹមត្រូវ ។ ដើម្បីទទួលបានការលើកលែងនេះ គ្រប់សហ-គ្រាសត្រូវអនុវត្តតាមវិធាន និងនីតិវិធីដែលមានចែងក្នុងប្រកាសលេខ ៦៣៨ សហវ.ប្រក ចុះថ្ងៃទី ៤ ខែ កក្កដា ឆ្នាំ ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការកាន់កាប់បញ្ជីកាគណនេយ្យមិនត្រឹមត្រូវ និងនីតិវិធីនៃការបង់ពន្ធអប្បបរមា ។

ចំពោះការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ១%, គឺជាជាយន្តការ, វិធាន និងនីតិវិធីនៃការប្រមូលពន្ធលើប្រាក់ចំណូល ដែលអនុវត្តនៅគ្រប់រដ្ឋបាលសារពើពន្ធទាំងអស់នៅលើសកលលោក ក្នុងការប្រមូលពន្ធលើប្រាក់ចំណូល ដោយគ្រាន់តែវិធីគណនាដោយឡែកៗពីគ្នាប៉ុណ្ណោះ ។ ការបង់ប្រាក់រំដោះ គឺតម្រូវឱ្យមានការបង់ទុកជាមុននូវប្រាក់កក់ដែលប្រហាក់ប្រហែលនឹងការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ។ ការបង់ប្រាក់កក់ជាមុន ឬប្រាក់រំដោះនេះធ្វើឡើងក្នុងគោលដៅដើម្បីរក្សាចីរភាពចំណូលចរន្តសម្រាប់រាជរដ្ឋាភិបាលប្រើប្រាស់ក្នុងខែនីមួយៗ ។

ជាការអនុវត្ត, ការប្រមូលប្រាក់រំដោះពន្ធលើប្រាក់ចំណូល មានចំណងទាក់ទងជាមួយនឹងពន្ធអប្បបរមាដូចខាងក្រោម៖

**ចំពោះសហគ្រាសដែលត្រូវបានលើកលែងពន្ធអប្បបរមា ១%៖**

- ប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងខែនីមួយៗនៃឆ្នាំជាប់ពន្ធ ត្រូវបានអនុញ្ញាតឱ្យទូទាត់កាត់កងជាមួយនឹងពន្ធលើប្រាក់ចំណូលត្រូវបង់នៅដំណាច់ឆ្នាំ,
- ក្នុងករណីពន្ធលើប្រាក់ចំណូលត្រូវបង់តិចជាងប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលបានបង់ក្នុងឆ្នាំជាប់ពន្ធ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលនៅសល់ត្រូវបានអនុញ្ញាតចាត់ជាឥណទានយកទៅប្រើប្រាស់សម្រាប់បង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងឆ្នាំបន្ទាប់,
- ក្នុងករណីពន្ធលើប្រាក់ចំណូលត្រូវបង់លើសពីប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលបានបង់ក្នុងឆ្នាំជាប់ពន្ធ សហគ្រាសត្រូវបង់ថែមតែចំនួនលើសប៉ុណ្ណោះ ។

**ចំពោះសហគ្រាសដែលមិនត្រូវបានលើកលែងពន្ធអប្បបរមា ១%៖**

- ក្នុងករណីពន្ធលើប្រាក់ចំណូលត្រូវបង់ តិចជាងប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលបានបង់ក្នុងខែនីមួយៗនៃឆ្នាំជាប់ពន្ធ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលទាំងនោះត្រូវបានចាត់ទុកជាពន្ធអប្បបរមា ហើយមិនអាចស្នើសុំជាឥណទាន ឬបង្វិលសងវិញឡើយ,

- ក្នុងករណីពន្ធលើប្រាក់ចំណូលត្រូវបង់ លើសពីប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលបានបង់ក្នុងឆ្នាំជាប់ពន្ធ សហគ្រាសត្រូវបង់ថែមតែចំនួនលើសប៉ុណ្ណោះ ។

***៣. ការបង់សេវាលើស្លាកយីហោ៖***

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានប្រគល់ភារកិច្ចឱ្យសិក្សាអំពីការយកកម្រៃសេវាជាន់គ្នានៃស្លាកយីហោនៅតាមមូលដ្ឋាននានា និងរាយការណ៍ជូនវេទិកាឱ្យបានមុនដំណាច់ឆ្នាំ ២០១៩ នេះ ។